ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៣-១៧៧ ប្រ.ក

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការស្ថិរភាពហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមប្រកាសលេខ ធ៨៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាត
- យោងតាមសំណើររបស់អគ្គលេខាធិការដ្ឋាន

## ស ម្រេ ច

**ប្រការ ១.-**

បង្កើតគណៈកម្មការស្ថិរភាពហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរង | ប្រធាន |
| ២. លោក គិម វ៉ាដា | អគ្គនាយកត្រួតពិនិត្យ | អនុប្រធាន |
| ៣. លោកស្រី ងួន សុខា | អគ្គនាយកបច្ចេកទេស | សមាជិក |
| ៤. លោកស្រី ជា សិរី | អគ្គនាយករងត្រួតពិនិត្យទីមួយ | សមាជិក |
| ៥. លោកស្រី ស្រី ស៊ីយុត | អគ្គនាយករងបច្ចេកទេសទីមួយ | សមាជិក |
| ៦. លោក រ័ត្ន សុវណ្ណនរៈ | អគ្គនាយករងត្រួតពិនិត្យ | សមាជិក |

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

៧. លោក ឃូ វុណ្ណី ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ សមាជិកអចិន្ត្រៃយ៍ ។

**ប្រការ ២.-**

សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីអវត្តមានរបស់ប្រធាន និងអាចអញ្ជើញមន្ត្រីជំនាញផ្សេងទៀតឲ្យចូលរួមក្នុងការប្រជុំតាមការចាំបាច់។

**ប្រការ ៣.-**

ការប្រជុំរបស់គណៈកម្មការត្រូវធ្វើយ៉ាងហោចណាស់រៀងរាល់ពីរខែម្តង។ ក្នុងករណីមានតម្រូវការចាំបាច់ ប្រធានគណៈកម្មការអាចកោះប្រជុំគណៈកម្មការនៅពេលណាក៏បាន ។

**ប្រការ ៤.-**

គណៈកម្មការមានមុខងារ និងភារកិច្ចដូចខាងក្រោមៈ

- កំណត់ ដឹកនាំ និងអនុវត្តគោលនយោបាយ សំដៅរក្សាស្ថិរភាពហិរញ្ញវត្ថុ ដើម្បីទ្រទ្រង់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព
- ដាក់នូវវិធានការចាំបាច់នានា ដើម្បីគាំទ្របេសកម្មរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការគ្រប់គ្រងសាច់ងាយស្រួល និងហានិភ័យនានាក្នុងវិស័យហិរញ្ញវត្ថុ
- ត្រួតពិនិត្យមើលពីអន្តរកម្មរវាងភ្នាក់ងារផ្សេងៗរបស់ទីផ្សារហិរញ្ញវត្ថុ គោលដៅរបស់នយោបាយរូបិយវត្ថុ និងឥទ្ធិពលមកលើប្រព័ន្ធធនាគារ និងវិភាគពីហានិភ័យដែលអាចកើតឡើង និង
- វិភាគ និងតាមដានស្ថិរភាពហិរញ្ញវត្ថុ ។

**ប្រការ ៥.-**

នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មការនេះ ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មការមានក្រុមជំនួយការមកពីនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៅក្រោមឱវាទរបស់ធនាគារជាតិនៃកម្ពុជា ។ ក្រុមការងារនេះត្រូវស្ថិតក្រោមការគ្រប់គ្រងទទួលខុសត្រូវរបស់ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ ។ សមាសភាពក្រុមការងារត្រូវតែងតាំងតាមសេចក្តីបង្គាប់ការរបស់ទេសាភិបាល និងមានមុខងារ ភារកិច្ចដូចខាងក្រោម :

- រៀបចំ និងផ្តល់ជូនគណៈកម្មការនូវព័ត៌មាន ព្រមទាំងទិន្នន័យពាក់ព័ន្ធនឹងស្ថានភាព និងនិន្នាការសេដ្ឋកិច្ច ដើម្បីបម្រើដល់ការសម្រេចចិត្តរបស់គណៈកម្មការក្នុងការកំណត់គោលដៅ យុទ្ធសាស្ត្រ និងវិធានការនានា
- សិក្សាពីស្ថិរភាពហិរញ្ញវត្ថុ និងធាតុផ្សេងៗ ដែលអាចមានឥទ្ធិពល និងអាចបណ្តាលឲ្យមានអស្ថិរភាពហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍អំពីលទ្ធផលនៃការប្រជុំរបស់គណៈកម្មការ ។

**ប្រការ ៦.-**

កំណត់ហេតុអង្គប្រជុំគណៈកម្មការត្រូវរៀបចំឲ្យរួចស្រេចយ៉ាងយូរមួយសប្តាហ៍ក្រោយពេលប្រជុំ ។

**ប្រការ ៧.~**

ប្រកាសស្តីពីការបង្កើតគណៈកម្មការស្ថិរភាពហិរញ្ញវត្ថុ លេខធ១-០១១-១១១ ប្រ.ក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.~**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងសាមីជននៅក្នុងប្រការ២ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៩.~**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣

**ទេសាភិបាល**

**ជា.ចាន់តូ**

**<u>កន្លែងទទួល</u>** :

- ដូចប្រការ ១ និងប្រការ ៨

"ដើម្បីអនុវត្ត"

- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>** :

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី